## អន្តរបុរី
### សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ អ្នកដឹកនាំខ្មែរត្រូវមានខន្តិធម៌ចំពោះការរិះគន់ពីអ្នកដទៃ ឲ្យស្របតាមទសពិធរាជធម៌១០យ៉ាង ដែលជាធម៌របស់អ្នកដឹកនាំ ។

website: www.hoksavann.org

ថ្ងៃទី២ មករា ២០០៨



ប្រមុខដឹកនាំរបស់រដ្ឋាភិបាលខ្មែរ ដោយមានរដ្ឋមន្ត្រីក្រសួងពត៌មានបន្ទរតាមផង បានពោលតិះដៀលលោកយ៉ាស៍-ហ្គាយតំណាងអង្គការសហប្រជាជាតិ ខាងការឃ្លាំមើលការគោរពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ថាលោកជាមនុស្សឈ្លើយព្រៃផ្សៃ គ្មានអារ្យធម៌ ហើយថាជនណាគាំទ្រលោកយ៉ាស៍-ហ្គាយ ជាជនថោកទាប ហើយរដ្ឋាភិបាលមិនឲ្យជួបឡើយ ។

ការតិះដៀលនេះ បន្ទាប់ពីលោកយ៉ាស៍-ហ្គាយមកធ្វើទស្សនកិច្ចចំនួន១០ថ្ងៃក្នុងអំឡុងខែធ្នូឆ្នាំ២០០៧នៅប្រទេសកម្ពុជា ដើម្បីពិនិត្យមើលការគោរពសិទ្ធិមនុស្សនៅប្រទេសនេះ ។ នៅពេលចប់ទស្សនកិច្ច លោកបានធ្វើសន្និសិទសារពត៌មាន ដោយរិះគន់រាជរដ្ឋាភិបាលខ្មែរ ដោយមិនសំចៃមាត់ថា មានអំពើរំលោភសិទ្ធិមនុស្សជាច្រើនទៅលើពលរដ្ឋខ្មែរគួរឲ្យអាណិតអាសូរ ។ ពលរដ្ឋខ្មែររស់នៅដោយការភ័យនឹងតុលាការដែលពុំមានយុត្តិធម៌ ។ ភ័យខ្លាចនឹងសមត្ថកិច្ចនគរបាល ដែលតែងតែប្រើអំពើហឹង្សាមកលើខ្លួន ។ ភ័យខ្លាចនឹងរដ្ឋអំណាចមូលដ្ឋាននិងពួកឈ្មួយ ព្រមទាំងអ្នកមានអំណាច ដែលរឹបយកដីធ្លី ។ សេចក្តីប្រកាសរបស់លោកនេះ បានទទួលការគាំទ្រពីអង្គការសិទ្ធិមនុស្សនៅប្រទេសកម្ពុជានិងសិទ្ធិមនុស្សអន្តរជាតិ ថាគាត់ពោលនេះមានភាពត្រឹមត្រូវ ។ សូមបញ្ជាក់ថា ការិយាល័យអង្គការសហប្រជាជាតិនេះបង្កើតឡើងនៅសម័យអ៊ុនតាក់ឆ្នាំ១៩៩៣ មានមុខងារពិនិត្យមើលស្ថានភាពសិទ្ធិមនុស្សនៅប្រទេស

កម្ពុជា ហើយធ្វើរបាយការណ៍ជូនអង្គការសហប្រជាជាតិ ។

សេចក្តីប្រកាសពត៌មានឆ្លើយតបទៅនឹងការតិះដៀលរបស់រាជរដ្ឋាភិបាលថា លោកតំណាងពិសេស គឺជាអ្នកជំនាញការឯករាជ្យមួយរូប ដែលត្រូវបានតែងតាំងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ លោកមានអាណត្តិតាមឃ្លាំមើលការគោរពសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាននៅក្នុងប្រទេសនេះ ដើម្បីជួយរដ្ឋាភិបាលនិងប្រជាជនកម្ពុជា ក្នុងការធានាថា ច្បាប់កម្ពុជានិងបទដ្ឋាននានាដែលរដ្ឋនេះបានទទួលយកត្រូវបានគោរពយ៉ាងមានប្រសិទ្ធិភាព ជំរុញឲ្យមានកិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុងវិស័យសិទ្ធិមនុស្ស និងរាយការណ៍ជាទៀងរាល់ឆ្នាំទៅក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ។

ក្នុងតួនាទីជាតំណាងពិសេស លោកមិនមែនជានយោជិតរបស់អង្គការសហប្រជាជាតិ ហើយក៏មិនទទួលប្រាក់បៀវត្សរ៍ដែរ ។ លោកយ៉ាស៍-ហ្គាយគឺជាសាស្ត្រាចារ្យផ្នែកច្បាប់រដ្ឋធម្មនុញ្ញ និងជាអ្នកការពារសិទ្ធិមនុស្សមួយរូប ដែលមានបទពិសោធន៍ច្រើនក្នុងការលើកស្ទួយនីតិរដ្ឋនៅប្រទេសជាច្រើន ។ លោកមិនតំណាងឲ្យប្រទេសកេនយ៉ាទេ ។ លោកតំណាងឲ្យគោលការណ៍សិទ្ធិមនុស្សទាំងឡាយ ដែលបានតម្កល់ក្នុងធម្មនុញ្ញសហប្រជាជាតិ ដែលក្នុងនោះ កម្ពុជាគឺជារដ្ឋសមាជិកមួយ ។ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ដែលសន្ធិសញ្ញាភាគច្រើន ត្រូវបានកម្ពុជាផ្តល់សច្ចាប័ន ហើយបានក្លាយជាផ្នែកមួយនៃច្បាប់កម្ពុជា ។

អ្នកដឹកនាំខ្មែរពោលថា លោកយ៉ាស៍-ហ្គាយជាមនុស្សឈ្លើយ ។ ពាក្យថាមនុស្សឈ្លើយនេះ មិនដឹងជាចង់ចាប់ផ្តាក់គាត់ត្រង់កន្លែងណាទេ ព្រោះពេលគាត់ទៅដល់ប្រទេសកម្ពុជា គាត់បានដាក់ពាក្យសុំជួបមន្ត្រីខ្មែរជាច្រើនរូប ជាពិសេសនាយករដ្ឋមន្ត្រី ប៉ុន្តែមិនបានទទួលចម្លើយតប ។ នេះជាការគួរសម មិនអាចចាត់ថា គាត់ជាមនុស្សឈ្លើយបានឡើយ ។ គេពុំអាចតិះដៀលគាត់ថា គាត់ជាមនុស្សព្រៃផ្សៃមើលងាយពលរដ្ឋខ្មែរបានទេ ។ តាមពិត គាត់ចុះមកជួយប្រជាពលរដ្ឋខ្មែរ កុំឲ្យមានការរំលោភពីអាជ្ញាធរខ្មែរពុំមែនគាត់មើលងាយពលរដ្ឋខ្មែរឡើយ ។ ផ្ទុយទៅវិញ អ្នកដែលរំលោភលើសិទ្ធិរបស់ពលរដ្ឋខ្លួនឯងនោះហើយ ជាមនុស្សព្រៃផ្សៃ ។ តិះដៀលគាត់ថា ជាមនុស្សគ្មានអារ្យធម៌ ។ គាត់ជាអ្នកចេះច្បាប់ ហើយយកចំណេះវិជ្ជាមកជួយពលរដ្ឋខ្មែរ ដោយចិត្តអាណិតអាសូរឲ្យចេញផុតពីសេចក្តីទុក្ខ ដែលត្រូវគេរំលោភធ្វើបាប ។ តាមព្រះពុទ្ធសាសនា ត្រូវចាត់ទុកគាត់ជាជនសប្បុរសមានអារ្យធម៌ខ្ពង់ខ្ពស់ ។ ឯអ្នកដែលរំលោភលើគេ ចាត់ជាជនអសប្បុរស ជាអនារិយជន ។ តិះដៀលជាតិគេថា ជាតិកេនយ៉ាជាជាតិថោកទាប មានការរំលោភសិទ្ធិមនុស្សដ៏ខ្លាំងក្លា ហេតុដូចម្តេចបានជាមិនជួយប្រទេសខ្លួន បែរជាមកចាប់អារម្មណ៍រឿងខ្មែរ ។ តាមពិត មុខងាររបស់លោកជាប្រេសិតពិសេសរបស់អង្គការស

ហប្រជាជាតិ តាមឃ្លាំមើលអំពីសិទ្ធិមនុស្សនិងសេរីភាពនៅប្រទេសកម្ពុជា ឯប្រទេសកេនយ៉ាជាប្រទេសកំណើតរបស់លោកជារឿងមួយផ្សេង ។

តាមព្រះពុទ្ធសាសនា មនុស្សខ្ពង់ខ្ពស់និងថោកទាប ពុំមែនស្ថិតនៅលើជាតិត្រកូលយសស័ក្តិ ទ្រព្យសម្បត្តិទេ តែត្រូវស្ថិតនៅលើអំពើដែលគេបានប្រព្រឹត្តិវិញទេ ។ យ៉ាងណាមិញ លោកយ៉ាស៍-ហ្គាយចាត់ជាមនុស្សខ្ពង់ខ្ពស់ថ្លៃថ្នូរ ព្រោះបានជួយដោះស្រាយសេចក្តីទុក្ខដល់អ្នកដែលមានទុក្ខ ដូចជួយដោះស្រាយសេចក្តីទុក្ខវេទនាដល់ពលរដ្ឋខ្មែរដែលត្រូវគេរំលោភដោយអយុត្តិធម៌ ។ អ្នកនាំពាក្យរបស់រាជរដ្ឋាភិបាលនិយាយថា សមាគមអាស៊ីអាគ្នេយ៍៩ទៀត ពុំមានការិយាល័យតំណាងអង្គការសហប្រជាជាតិដូចខ្មែរទេ ។ តាមពិត ប្រទេសទាំង៩នោះ ពុំមានព្រឹត្តិការណ៍ដូចប្រទេសខ្មែរ ។ កិច្ចព្រមព្រៀងសន្តិភាពប្រទេសកម្ពុជាឆ្នាំ១៩៩១នៅទីក្រុងប៉ារីស តម្រូវឲ្យមានការិយាល័យនេះ ដើម្បីពិនិត្យមើលការគោរពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ។ ប្រមុខរាជរដ្ឋាភិបាលខ្មែរពោលថា ជនណាគាំទ្រលោកយ៉ាស៍-ហ្គាយជាជនថោកទាប ។ តាមការសង្កេត អង្គការសិទ្ធិមនុស្សនៅកម្ពុជា ក៏ដូចគ្នានឹងអង្គការសិទ្ធិមនុស្សអន្តរជាតិ សុទ្ធតែបានគាំទ្ររបាយការណ៍របស់លោកយ៉ាស៍-ហ្គាយ ថាជាការពិត ។ ដូច្នេះសំដីនេះ បានប៉ះពាល់ទៅលើអ្នកការពារសិទ្ធិមនុស្សដ៏ធ្ងន់ ជាពិសេសអង្គការសហប្រជាជាតិ ។ អ្នកនាំពាក្យរាជរដ្ឋាភិបាលខ្មែរនិយាយថា តំណាងអង្គការសហប្រជាជាតិមកប្រទេសកម្ពុជា មិនបានជួយអ្វីខ្មែរទេ គឺមកជេររដ្ឋាភិបាលខ្មែរប៉ុណ្ណោះ ។ តាមពិត លោកយ៉ាស៍-ហ្គាយមកជួយរាជរដ្ឋាភិបាលនិងប្រជាពលរដ្ឋខ្មែរ ឲ្យគោរពសិទ្ធិមនុស្ស ដើម្បីឲ្យប្រទេសកម្ពុជាមានមុខមាត់ល្អក្នុងឆាកអន្តរជាតិ ។ គួរតែត្រេកអរ និងដឹងគុណគាត់ ។

តាមសេចក្តីប្រកាសពត៌មានរបស់តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានប្រកាសចុងអត្ថបទថា ក្នុងការពិនិត្យពិច័យដ៏ស្មោះត្រង់ លើរបាយការណ៍របស់លោកតំណាងពិសេសមុនៗ ចាប់ពីឆ្នាំ១៩៩៣មកបង្ហាញថាការរីកចំរើនក្នុងវិស័យនីតិរដ្ឋ និងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ គឺជារបាយការណ៍យ៉ាងត្រឹមត្រូវ ដែលរបាយការណ៍ទាំងនោះ តម្រូវឲ្យធ្វើការវាយតម្លៃប្រកបដោយភាពយុត្តិធម៌ ។ ទន្ទឹមគ្នានេះ បញ្ហាដែលជាកង្វល់ដូចដែលបានរាយការណ៍នៅក្នុងដំណើរទស្សនកិច្ចកន្លងមក នៅតែបន្តកើតមានដដែល ។ បញ្ហាទាំងនេះ គឺជាកង្វល់ដ៏ធ្ងន់សំរាប់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋខ្មែរជាច្រើននាក់ ។ បញ្ហាទាំងនេះមិនអាចលុបបំបាត់ដោយឯកឯងឡើយ តម្រូវឲ្យមានដំណោះស្រាយ ដូចសុភាសិតខ្មែរពោលថា ដំរីងាប់មិនអាចយកចង្អេរបាំងបានឡើយ ។ តួនាទីរបស់លោកតំណាងពិសេស គឺស្វែងយល់អំពីកង្វល់ទាំងនេះ ដើម្បីទាញចំណាប់អារម្មណ៍របស់រដ្ឋាភិបាលចំពោះបញ្ហាទាំងនេះ និងធ្វើការជាមួយរដ្ឋាភិបាល ប្រជាពលរដ្ឋខ្មែរ និងសហគមន៍អន្តរជាតិ ដើម្បីដោះស្រាយបញ្ហាទាំងនេះ។

ប្រកាសនោះបានបន្តទៀតថា លោកតំណាងពិសេសមិនបានអំពាវនាវ ឲ្យសហគមន៍អន្តរជាតិកាត់ផ្តាច់ជំនួយរបស់ខ្លួនដល់កម្ពុជានោះទេ ។ ផ្ទុយទៅវិញ លោកបានជំរុញលើកទឹកចិត្តដល់រដ្ឋជាសមាជិកទាំងអស់ ដែលជាភាគពួកិច្ចក្នុងធម្មនុញ្ញសហប្រជាជាតិ ឲ្យបន្តកិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយថែមទៀត ។

ដូចពោលមកហើយបញ្ជាក់ថា លោកយ៉ាស៍-ហ្គាយពុំមែនមកមើលងាយខ្មែរទេ គឺមកជួយខ្មែរ ឲ្យប្រទេសកម្ពុជាទៅជាប្រទេសនីតិរដ្ឋ គ្រាន់តែលោកពុំបានពោលសរសើររាជរដ្ឋាភិបាលខ្មែរ ត្រង់កន្លែងដែលធ្វើត្រូវប៉ុណ្ណោះ គឺលោកនិយាយត្រង់កន្លែងដែលធ្វើខុសតែម្តង ដើម្បីកុំឲ្យខាតពេល ដែលទង្វើនេះធ្វើឲ្យអ្នកដឹកនាំខ្មែរប្រកាន់ខឹង ។ ការរំលោភយកដីរបស់ពលរដ្ឋពីអ្នកមានអំណាច ក្រុមប៉ូលិសបានប្រើអំពើហិង្សាទៅលើប្រជាពលរដ្ឋ ដែលក្រោកឡើងទាមទារដីធ្លីខ្លួន ដែលត្រូវបាត់បង់ បានត្រូវវាយប្រហារមានរបួសរហូតដល់ស្លាប់ក៏មាន។ បែរមកពឹងលើតុលាការៗបានកាត់ឲ្យអ្នកមានអំណាចឈ្នះ ។ តើទាំងអស់នេះ ដែលគាត់និយាយជាការពិតឬទេ ?

ដូច្នេះគួររដ្ឋាភិបាលខ្មែរ មុនសំរេចបែបណាមួយអំពីបញ្ហាសិទ្ធិមនុស្សនេះ គប្បីពិចារណាឲ្យបានល្អិតល្អន់ ព្រោះកុំឲ្យខូចកិត្តិយសប្រទេសកម្ពុជា ។ គួរជួបពិភាក្សាជាមួយតំណាងអង្គការសហប្រជាជាតិនេះ ដើម្បីរកដំណោះស្រាយ ។ ការជៀសវាងមិនព្រមជួបពុំមែនជាដំណោះស្រាយឡើយ ។ បើទទូចឲ្យផ្លាស់លោកយ៉ាស៍-ហ្គាយ ហើយប្តូរលោកណាម្នាក់ទៀត គេនៅតែនិយាយការពិតដូច្នេះដដែល ដូចជាលោក ពីទ័រ-ឡឺព្រិច តំណាងពិសេសលើកមុន ក៏និយាយដូចគ្នានឹងលោកយ៉ាស៍-ហ្គាយដែរ ។ ដូច្នេះនៅតែមិនត្រូវគ្នានឹងរដ្ឋាភិបាលដដែល ពោលគឺគេមិនពោលសរសើររដ្ឋាភិបាល ខុសពីការពិត ដើម្បីតម្រូវចិត្តអ្នកដឹកនាំខ្មែរឡើយ ។ កំហុសដ៏ធ្ងន់មួយទៀតរបស់ប្រមុខរដ្ឋាភិបាលខ្មែរ គឺតិះដៀលពូជអំបូររបស់ប្រទេសកេនយ៉ាទីក្រុងណៃរ៉ូប៊ី របស់លោកយ៉ាស៍-ហ្គាយ ថាជាតំបន់ចោរប្លន់អន់ជាងខ្មែរ១០០ដង ហើយបញ្ជាឲ្យទូរទស្សន៍ចាក់ផ្សាយកន្លែងណាដែលអាក្រក់របស់ប្រទេសកេនយ៉ាទៀតផង ។ បើអ្នកដឹកនាំខ្មែរសំរេចឲ្យបិទទ្វារការិយាល័យនេះវិញ រឹតតែអាក្រក់ណាស់ទៅទៀត ព្រោះគេមើលឃើញថា អ្នកដឹកនាំខ្មែរទទួលមេដឹកនាំផ្តាច់ការឃោធាភូមា ឲ្យមកធ្វើទស្សនកិច្ចនៅកម្ពុជា តែបែរជាមិនទទួលលោកតំណាងពិសេស ដែលឃ្លាំមើលសិទ្ធិមនុស្សទៅវិញ ដែលនាំឲ្យគេសង្ស័យថា បំណងបិទបាំងអំពើអាក្រក់របស់ខ្លួនមកលើពលរដ្ឋខ្មែរ ។

អ្នកដឹកនាំខ្មែរបច្ចុប្បន្ននិងទៅអនាគត គួរប្រើវិចារណញ្ញាណ ពិចារណាឲ្យបានល្អិតល្អន់ មុននឹងមានប្រតិកម្មទៅលើការរិះគន់របស់អ្នកដទៃ ដូចពាក្យខ្មែរពោលថា សក់មួយសរសៃជ្រៀកជាងប់ ។ ព្រោះមិនមែនជារូបវន្តបុគ្គល គឺជានីតិបុគ្គលសាធារណៈ តំណាងប្រជាជាតិខ្មែរទាំងមូល ។ បើសំរេចចិត្តខុស វានាំឲ្យខូចកិត្តិយសប្រទេសកម្ពុជា ។

មិនមែនតែបច្ចុប្បន្ននេះទេ ដែលអ្នកដឹកនាំខ្មែរមានការក្រេវក្រោធចំពោះការរិះគន់ពីអ្នកដទៃ គឺមានតាំងពីសម័យសង្គមរាស្ត្រនិយម សារពត៌មានណាសរសេររិះគន់រាជរដ្ឋាភិបាលសម័យនោះ ត្រូវបិទមិនឲ្យទិដ្ឋាការចូលប្រទេសកម្ពុជាឡើយ ។ បើកឲ្យចូលតែសារ-ពត៌មានណាដែលសរសើររាជរដ្ឋាភិបាល ។ ហើយយកសារពត៌មានដែលសរសេរសរសើររាជរដ្ឋាភិបាល មកអានដោយផ្ទាល់ខ្លួនផ្សាយតាមវិទ្យុជាតិ ដើម្បីឲ្យប្រជារាស្ត្រខ្មែរស្តាប់ទៀតផង ។ មិនតែប៉ុណ្ណោះ ជេរអាមេរិកាំងថា «អាគាំង», ជេរថៃ ជេរយួនខាងត្បូង គាំទ្រចិនកុម្មុយនិស្ត ដែលបោះរោងចក្រកញ្ចាស់ៗពីរបីឲ្យ គ្រាន់តែទិញគ្រឿងយកមកផ្លាស់ ថ្លៃស្មើនឹងម៉ាស៊ីនដែលផ្តល់ឲ្យនោះ ។

ការជេរគេនោះ នាំឲ្យគេស្អប់ខ្មែរ គឺបង្កើតសត្រូវឲ្យខ្មែរ ដោយសារតែការឆេវឆាវក្រោធខឹងខ្វះវិចារណញ្ញាណរបស់អ្នកដឹកនាំខ្មែរ ។ ទីបំផុត សេដ្ឋកិច្ចត្រូវធ្លាក់ចុះ ដោយសារការក្ដេងក្ដាងដូចក្អាត់នៅក្នុងក្រុមរបស់អ្នកដឹកនាំខ្មែរ ជាបុព្វហេតុឲ្យកើតព្រឹត្តិការណ៍ឆ្នាំ១៩៧០ ។ ឥឡូវនេះ មេរៀនបានកើតឡើងវិញ ដោយប្រមុខរាជរដ្ឋាភិបាលខ្មែរបច្ចុ-ប្បន្នតិះដៀលលោកយ៉ាស៍-ប្គាយ ដោយសារលោកនិយាយការពិត ដែលធ្វើឲ្យរាជរដ្ឋាភិបាលខ្មែរមិនពេញចិត្ត ។

អ្នកដឹកនាំខ្មែរគ្រប់ជំនាន់ គួរប្រតិបត្តិតាមធម៌ព្រះពុទ្ធ ព្រោះជាអ្នកគោរពព្រះពុទ្ធសាសនា ។ ធម៌សំរាប់អ្នកដឹកនាំ ដែលគប្បីអនុវត្តតាមមានជាច្រើនយ៉ាង ក្នុងពេលនេះសូមលើកតែធម៌មួយ ដើម្បីឲ្យស្របតាមប្រធានបទនេះ គឺខន្តិធម៌ ដែលមាននិយាយក្នុងទសពិធរាជធម៌១០យ៉ាង ។ ខន្តិធម៌នេះ ជាធម៌មានសារៈសំខាន់ណាស់សំរាប់មេដឹកនាំអនុវត្ត គឺចេះអត់ធ្មត់ចំពោះអំពើឬសំដីអ្នកដទៃ ដោយតបទៅវិញដោយសំដីទន់ភ្លន់ ដោយមេត្តាធម៌ ស្របតាមពុទ្ធភាសិតមួយបទទៀតពោលថា ឈ្នះមនុស្សក្រោធដោយមិនក្រោធតប ។ បើកាន់ធម៌នេះបាន នោះជាកិត្តិយសខ្លាំងណាស់របស់អ្នកដឹកនាំ មិនថាតែមនុស្សទេដែលសរសើរ ទោះបីទេវតាក៏ប្រទានពរសព្វសាធុការដែរ ។ ដូច្នេះគួរទុកលោកតំណាងពិសេសអង្គការសហប្រជាជាតិ ហើយចាប់ពិភាក្សាគ្នាដោះស្រាយបញ្ហា ។៚

❄ ❄

❄